# I- ផ្នែកការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៤*

### អនុក្រឹត្យលេខ ១១ អនក្រ
### ស្តីពីការបង្កើតគណៈកម្មការចំរុះបង្ការបង្ក្រាប
### សកម្មភាពលួចឆក់ប្លន់ប្រដាប់អាវុធ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យសំណូមពរចាំបាច់នៃការការងារបោសសំអាតសកម្មភាពលួចឆក់ប្លន់ប្រដាប់អាវុធក្នុងក្របខ័ណ្ឌទូទាំងប្រទេស សំដៅការពារសន្តិសុខ អាយុជីវិត ទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ អង្គការអន្តរជាតិ ជនបរទេសដែលបាននិង កំពុងរួមចំណែកយ៉ាងសកម្មក្នុងបុព្វហេតុសន្តិភាព និង កិច្ចអភិវឌ្ឍន៍ប្រទេសជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ :** - ត្រូវបង្កើតគណៈកម្មការចំរុះមួយនៅថ្នាក់ក្រសួង ថ្នាក់ខេត្ត ក្រុងនិងស្រុក ខ័ណ្ឌ ទីរួមខេត្តដើម្បីបង្ការបង្ក្រាប សកម្មភាពលួច ឆក់ ប្លន់ ប្រដាប់អាវុធក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួន ។

<u>សមាសភាពគណៈកម្មការចំរុះទាំងនោះរួមមាន :</u>

<u>ក_គណៈកម្មការចំរុះថ្នាក់ក្រសួង " ហៅកាត់គណៈកម្មការចំរុះ ក "</u>

១_ឯកឧត្តម ឧត្តមសេនីយអង្គទ័ព **ស៊ិន សេន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន

២_ឯកឧត្តម ឧត្តមសេនីយអង្គទ័ព **គៀង ម៉ាង** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

៣_លោកនាយឧត្តមសេនីយ **មាស សុភា** អគ្គសេនាធិការរង កងយោធពលខេមរភូមិន្ទ ជាអនុប្រធាន

៤_លោកនាយ ឧត្តមសេនីយ **លី សេងហុង** អគ្គសេនាធិការរងកងយោធពលខេមរភូមិន្ទ ជាអនុប្រធាន

៥_លោកឧត្តមសេនីយឯក **រ៉ាំ ឌិន** មេបញ្ជាការយោធពលខេមរភូមិភាគពិសេស ជាសមាជិក

៦_លោក ឧត្តមសេនីយឯក **ទេស ចយ** ប្រធាននាយកដ្ឋាននគរបាលការពារ ជាសមាជិក

៧_លោក ឧត្តមសេនីយឯក **នេត សាវឿន** ស្នងការនយោបាយរាជធានីភ្នំពេញ ជាសមាជិក

៨_លោក ឧត្តមសេនីយទោ **កែច សាមួន** មេបញ្ជាការកងរាជអាវុធហត្ថ ជាសមាជិក

៩_លោក ឧត្តមសេនីយឯក **ម៉ៅ ចន្ទតារា** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ និងសេដ្ឋកិច្ច ជាសមាជិក

១០_លោក ឧត្តមសេនីយទោ **សាច សុខ** ប្រធានស្ថាប័នអយ្យការយោធា ជាសមាជិក

១១_លោក ឧត្តមសេនីយឯក **គន្ធ សំអឿន** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម ជាសមាជិក

១២_លោក ឧត្តមសេនីយឯក **សុខ ផល** ប្រធាននាយកដ្ឋានចារកម្ម ជាសមាជិក

១៣_លោក ឧត្តមសេនីយឯក **យុន ឈុន្នី** ប្រធាននាយកដ្ឋាននគរបាលសណ្តាប់ធ្នាប់សង្គម ជាសមាជិក

១៤_លោក ឧត្តមសេនីយឯក **ហេង ហាក់** អនុប្រធានមន្ទីរក្រសួងមហាផ្ទៃ ជាសមាជិក

<u>ខ_គណៈកម្មការចំរុះថ្នាក់ខេត្តក្រុង " ហៅកាត់គណៈកម្មការចំរុះខ "</u>

_លោកអភិបាលខេត្ត ជាប្រធាន

-មេបញ្ជាការតំបន់ប្រតិបត្តិការសឹកប្រចាំខេត្ត ក្រុង ជាអនុប្រធាន

-លោកស្នងការនគរបាលខេត្ត ជាអនុប្រធាន

-លោកអភិបាល ស្រុក ខ័ណ្ឌ ទីរួមខេត្ត ជាអនុប្រធាន

គ-គណៈកម្មការចំរុះថ្នាក់ ស្រុក ខ័ណ្ឌ ទីរួមខេត្ត " ហៅកាត់គណៈកម្មការចំរុះគ "

-លោកអភិបាលស្រុក ខ័ណ្ឌ ទីរួមខេត្ត ជាប្រធាន

-លោកបញ្ជាការអង្គភាពទ័ពឈរជើងក្នុងភូមិសាស្ត្រ ជាអនុប្រធាន

-លោកអធិការនគរបាលស្រុក ជាអនុប្រធាន

-អង្គភាពពាក់ព័ន្ធផ្សេងទៀតដែលចាំបាច់ ជាសមាជិក

មាត្រា ២ :-គណៈកម្មការចំរុះថ្នាក់ណា ស្ថិតក្រោមការដឹកនាំរបស់សមត្ថកិច្ចថ្នាក់នោះ ធ្វើសកម្មភាពដោយសហការ ជិតស្និតជាមួយបណ្តាកងកំលាំងជំនាញ និងស្ថាប័ន ក្រសួង មន្ទីរ អង្គភាពដែលមានការពាក់ព័ន្ធ ។

មាត្រា ៣ : -គណៈកម្មការចំរុះ " ក " មានភារកិច្ចដឹកនាំបញ្ជាលើសកម្មភាពបង្ការបង្ក្រាបអំពើលួចឆក់ប្លន់ប្រដាប់អាវុធ រំសាយកំលាំងប្រដាប់អាវុធក្រៅច្បាប់ ព្រមទាំងកំណត់ទិសដៅ វិធានការ និងណែនាំតាមដានត្រួតពិនិត្យការអនុវត្តន៍របស់គណៈកម្មការ " ខ.គ " ។

មាត្រា ៤ : -គណៈកម្មការចំរុះ " ខ.គ " មានភារកិច្ចបំផុសចលនាប្រជារាស្ត្រចូលរួមទូលាយក្នុងកិច្ចការបង្ការ និង បង្ក្រាបអំពើលួចឆក់ប្លន់ប្រដាប់អាវុធ រំសាយកំលាំងប្រដាប់អាវុធក្រៅច្បាប់ ។ បង្កើនការងារគ្រប់គ្រងមនុស្សគ្រប់អាវុធជាតិផ្ទុះ គ្រប់គ្រងមធ្យោបាយដឹកជញ្ជូន....... ។ ប្រមូលផ្តុំកំលាំងចំរុះកងកំលាំងខេមរភូមិន្ទ នគរបាលជាតិ កង រាជអាវុធហត្ថជាតិធ្វើសកម្មភាពល្បាត ត្រួតពិនិត្យដកហូតអាវុធជាតិផ្ទុះ ស្ទាក់ចាប់ពួក លួច ឆក់ ប្លន់និងអន្តរាគមន៍ក្នុងករណីចាំបាច់ ។ រួមជាមួយកំលាំង ជំនាញដែលមានស្រាប់ស៊ើបអង្កេត ស្រាវជ្រាវ កសាងសំណុំរឿងករណីបទល្មើសដាក់ស្តែងចោទប្តឹងទៅតុលាការ ។

**មាត្រា ៥** :_គណៈកម្មការចំរុះមានសិទ្ធ:

_ប្រើប្រាស់ត្រាផ្លូវការតាមថ្នាក់ និង ជំនាញនិមួយៗដែលមានស្រាប់ ។

_បង្កើតក្រុមជំនាញរបស់ខ្លួន ដើម្បីជំនួយការ ។

_មានស្នាក់នៅក្នុងស្ថាប័ន នគរបាលជាតិ យោធា ។

_ធ្វើរបាយការណ៍ពីសកម្មភាពការងារ និង សភាពការណ៍ជូនមកថ្នាក់លើជាប្រចាំតាមលំដាប់ថ្នាក់ ។

**មាត្រា ៦** :_សមាជិកគ្រប់រូបនៃគណៈកម្មការចំរុះ ត្រូវចូលរួមធ្វើការងារតាមការអញ្ជើញ និងការណែនាំរបស់ប្រធានគណៈកម្មការហើយត្រូវទទួលខុសត្រូវចំពោះថ្នាក់លើរបស់ខ្លួន ។

**មាត្រា ៧** :_សហរដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារប្រទេស លោកអភិ បាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់បំផុត ។

**មាត្រា ៨** :_បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩** :_អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រហត្ថលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ១៨ អនក្រ

រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា